**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:១៧០.សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មការសម្រាប់គម្រោងប្រព័ន្ធទូរគមនាគមន៍ សម្រាប់វិស័យការពារជាតិ និងសន្តិសុខជាតិក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានរវាងសាធារណរដ្ឋប្រជាមានិតចិន ជាមួយព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/ ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមសំណើរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**សម្រេច**

**ប្រការ ១._**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការសម្រាប់គម្រោងប្រព័ន្ធទូរគមនាគមន៍ សម្រាប់វិស័យការពារជាតិ និងសន្តិសុខជាតិក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការហិរញ្ញប្បទាន រវាងសាធារណរដ្ឋប្រជាមានិតចិន ជាមួយព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម ៖

១ - ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រធាន

២ - ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អនុប្រធានអចិន្ត្រៃយ៍

៣ - ឯកឧត្តម **ភាន ច័ន្ទមេត្តា** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អនុប្រធាន

៤ - ឯកឧត្តមនាយឧត្តមសេនីយ៍ **តេង សាវង្ស** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៥ - ឯកឧត្តមនាយឧត្តមសេនីយ៍ **អ៊ី ឈាន** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

៦ - ឯកឧត្តម **ម៉ូង ចរិយា** ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា សមាជិក
៧ - ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៨ - ឯកឧត្តម **ជុន វ៉ាត** អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

**ប្រការ ២ ._**

គណៈកម្មការមានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេស ដើម្បីជួយរៀបចំការសិក្សាស្តីពីប្រព័ន្ធទូរគមនាគមន៍ សម្រាប់វិស័យការពារជាតិ និងសន្តិសុខជាតិ ។

**ប្រការ ៣ ._**

គណៈកម្មការមានសិទ្ធិអញ្ជើញមន្ត្រីជំនាញជាតិ និងអន្តរជាតិ ដើម្បីចូលរួមផ្តល់យោបល់លើប្រធានបទនេះ ។

**ប្រការ ៤ ._**

សេចក្តីសម្រេចលេខ ១៨ សសរ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ និងប្រការ ២ នៃសេចក្តីសម្រេចលេខ ១៦២ សសរ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ